# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# សកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាន
# គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ប្រចាំឆ្នាំ ២០០៥

គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា( **គ.ទ.ក** ) ត្រូវបានបង្កើតឡើងសំរាប់គ្រប់គ្រងដំណើរការនៃការធានានិងលើកកំពស់គុណភាពអប់រំឧត្តមសិក្សានៅកម្ពុជា ឱ្យមានប្រសិទ្ធិភាពខ្ពស់ស្របតាមស្តង់ដារអន្តរជាតិ ។ **គ.ទ.ក** មានអគ្គលេខាធិការដ្ឋានមួយជាអង្គភាពប្រតិបត្តិ ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការបំពេញបេសកកម្មនិងអនុវត្តរាល់ភារកិច្ចទាំងឡាយរបស់គណៈកម្មាធិការនេះ ។ នៅក្នុងឆ្នាំ ២០០៥ កន្លងមក អគ្គលេខាធិការដ្ឋានបានបំពេញបេសកកម្មនិងអនុវត្តរាល់ភារកិច្ចរបស់ខ្លួនក្នុងការកសាងបទដ្ឋានគតិយុត្តិនានាសំដៅពង្រឹងគុណភាពអប់រំឧត្តមសិក្សា និង ជំរុញការអនុវត្តភារកិច្ចឱ្យសំរេចបានជោគជ័យតាមផែនការការងាររបស់ខ្លួន ទោះបីជាមានការខ្វះខាតថវិកា សំភារៈ និង ធនធានមនុស្សយ៉ាងណាក៏ដោយ ។ ក្រៅពីនេះ អគ្គលេខាធិការដ្ឋានបានធ្វើកិច្ចសហការ និង ទំនាក់ទំនងជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ពិសេសក្រសួងអប់រំ យុវជន និងកីឡា និង គ្រប់គ្រឹះស្ថានឧត្តមសិក្សានានា បានធ្វើកិច្ចសហប្រតិបត្តិការនិងទំនាក់ទំនងជាមួយធនាគារពិភពលោក អង្គការអន្តរជាតិនានា ជាពិសេសអង្គការ APQN (Asia Pacific Quality Network) និងប្រទេសផ្សេងៗទៀត ដើម្បីស្វែងរកជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុក្នុងការជួយពង្រឹងសម្ថភាពរបស់ខ្លួនទាំងមូលដ្ឋានសំភារៈ ធនធានមនុស្ស និងបច្ចេកទេសនៃដំណើរការទទួលស្គាល់គុណភាពអប់រំ ។

## I- លទ្ធផលការងារ

### ១-ការងាររៀបចំស្តង់ដារនិងការទទួលស្គាល់គុណភាពអប់រំ

#### ក-ការងារឆ្នាំសិក្សាមូលដ្ឋាន

យោងតាមស្មារតីនៃព្រះរាជក្រឹត្យ លេខ ០៣០៣/១២៩/រកត ចុះថ្ងៃទី ៣១ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានគឺជាឆ្នាំទីមួយនៃការសិក្សាថ្នាក់បរិញ្ញាប័ត្ររបស់និស្សិត ។ ដោយមានការយល់ព្រមពី**គ.ទ.ក** គ្រឹះស្ថានឧត្តមសិក្សាដែលដំណើរការឆ្នាំសិក្សាមូលដ្ឋានអាចចេញវិញ្ញាបនប័ត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋានជូនដល់និស្សិត ដែលបានបញ្ចប់ការសិក្សាប្រកបដោយជោគជ័យ ។

ការអនុវត្តថ្នាក់ឆ្នាំសិក្សាមូលដ្ឋានក្នុងដំណាក់កាលដំបូង អគ្គលេខាធិការដ្ឋាន **គ.ទ.ក** បានបំពេញភារកិច្ចនិងរៀបចំបទដ្ឋានមួយចំនួន ដូចខាងក្រោម:

- នៅថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០០៥បាន **គ.ទ.ក** បានចេញសេចក្តីជូនដំណឹងដើម្បីឱ្យគ្រឹះស្ថានឧត្តមសិក្សាទាំងអស់ចាប់ផ្តើមអនុវត្តឆ្នាំសិក្សាមូលដ្ឋាន ចាប់ពីឆ្នាំសិក្សា ឆ្នាំ ២០០៥-២០០៦ តទៅ ។

-អគ្គលេខាធិការដ្ឋានបានពិនិត្យនិងកែសំរួល លើកម្មវិធីថ្នាក់ឆ្នាំសិក្សាមូលដ្ឋានរបស់គ្រឹះស្ថានឧត្តមសិក្សានិងដាក់ជូន **គ.ទ.ក** ពិនិត្យនិងសំរេច បានចំនួន ៣៥ គ្រឹះស្ថានឧត្តមសិក្សា ក្នុងចំណោម៣៧គ្រឹះស្ថានឧត្តមសិក្សាដែលបានដាក់ពាក្យស្នើសុំការយល់ព្រមលើកម្មវិធីថ្នាក់ឆ្នាំសិក្សាមូលដ្ឋានពី**គ.ទ.ក**។បច្ចុប្បន្ននេះមានគ្រឹះស្ថានឧត្តមសិក្សាទាំងសាធារណៈនិងឯកជន ដែលកំពុងដំណើរការបណ្តុះបណ្តាលកំរិតបរិញ្ញប័ត្រឡើងទៅនៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ចំនួន ៥១គ្រឹះស្ថានឧត្តមសិក្សា។

- នៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០០៥ **គ.ទ.ក** បានចេញសៀវភៅណែនាំលំអិតស្តីពីដំណើរការថ្នាក់ឆ្នាំសិក្សាមូលដ្ឋានសំរាប់គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ និង សៀវភៅណែនាំស្តីពីដំណើការវាយតំលៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន សំរាប់មន្ត្រីវាយតំលៃ។ សៀវភៅណែនាំនេះ មានគោលបំណងឱ្យគ្រឹះស្ថានឧត្តមសិក្សាដែលដំណើរការឆ្នាំសិក្សាមូលដ្ឋានធ្វើការវាយតំលៃខ្លួនឯង (Self-Assessment) តាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ មុនការចុះពិនិត្យផ្ទៀងផ្ទាត់របស់ក្រុមមន្ត្រីវាយតំលៃ (Assessors) ដើម្បីអនុញ្ញាតឱ្យគ្រឹះស្ថានឧត្តមសិក្សានោះចេញវិញ្ញាបនប័ត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋានដល់និស្សិត។

- នៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០០៥ អគ្គលេខាធិការដ្ឋានបានរៀបចំសិក្ខាសាលា ស្តីពីរបៀបនៃការសរសេររបាយការណ៍ស្វ័យវាយតំលៃ ( Self assessment )ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៅតាមគ្រឹះស្ថានឧត្តមសិក្សាដែលឧបត្ថម្ភដោយយូណេស្កូ ភ្នំពេញ នៅសាលសន្និសិទ្ធព្រឹទ្ធសភា។

ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន គឺជាបរិបទថ្មីមួយទៀតសំរាប់ **គ.ទ.ក** និងគ្រឹះស្ថានឧត្តមសិក្សាទាំងអស់។ ហេតុនេះការអនុវត្តថ្នាក់ឆ្នាំសិក្សាមូលដ្ឋានក្នុងដំណាក់ដំបូងនេះបានជួបការលំបាកមួយចំនួនដូចជាៈការបែងចែកភារកិច្ចទទួលខុសត្រូវថ្នាក់ឆ្នាំសិក្សាមូលដ្ឋានរវាង **គ.ទ.ក** និងក្រសួងអប់រំ យុវជន និងកីឡា និង ការរៀបចំកម្មវិធីថ្នាក់ឆ្នាំសិក្សាមូលដ្ឋានរបស់គ្រឹះស្ថានឧត្តមសិក្សាទាំងនោះមានការខុសឆ្គងច្រើន ហើយត្រូវបានស្នើឱ្យកែសំរួលច្រើនលើកច្រើនសារ ដោយសារការយល់ដឹងរបស់គ្រឹះស្ថានទាំងនោះលើបញ្ហានេះពុំទាន់យល់ច្បាស់។

**ខ-មន្ត្រីវាយតំលៃគុណភាពអប់រំឧត្តមសិក្សា** (Assessors)

យោងតាមស្មារតីនៃព្រះរាជក្រឹត្យ លេខ ០៣០៣/១២៩/រកត ចុះថ្ងៃទី ៣១ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា **គ.ទ.ក** ត្រូវជ្រើសរើសមន្ត្រីវាយតំលៃគុណភាពអប់រំឧត្តមសិក្សា ដើម្បីធានាលើប្រសិទ្ធភាព តម្លាភាព និងយុត្តិធម៌ ក្នុងដំណើរការនៃការចុះវាយតំលៃពីខាងក្រៅគ្រឹះស្ថាន ឧត្តមសិក្សា។ មន្ត្រីវាយតំលៃមានតួនាទីយ៉ាងសំខាន់ ក្នុងការចុះពិនិត្យនិងផ្ទៀងផ្ទាត់របាយការណ៍វាយតម្លៃខ្លួនឯងទៅនឹងភាពពិតជាក់ស្តែងនៃគ្រឹះស្ថានឧត្តមសិក្សា ព្រមទាំងធ្វើរបាយការណ៍និងលើកអនុសាសន៍ជូន គ.ទ.ក ដើម្បីធ្វើជាមូលដ្ឋានក្នុងការសំរេចផ្តល់ការទទួលស្គាល់គុណភាពអប់រំ។

ក្នុងដំណើរការជ្រើសរើសមន្ត្រីវាយតំលៃគុណភាពអប់រំឧត្តមសិក្សា អគ្គលេខាធិការដ្ឋាន **គ.ទ.ក** បានបំពេញភារកិច្ចនិងរៀបចំបទដ្ឋានមួយចំនួន ដូចខាងក្រោមៈ

- នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៥ **គ.ទ.ក** បានចេញសេចក្តីសំរេចស្តីពីការជ្រើសរើសមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា។

-នៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៥ អគ្គលេខាធិការដ្ឋាន **គ.ទ.ក** បានចេញសេចក្តីជូនដំណឹងស្តីពី ការជ្រើសរើសមន្ត្រីវាយតំលៃគុណភាពអប់រំឧត្តមសិក្សារបស់**គ.ទ.ក**។

- នៅថ្ងៃ ១០ខែ សីហា ឆ្នាំ ២០០៥ អគ្គលេខាធិការដ្ឋាន **គ.ទ.ក** បានចេញសេចក្តីសំរេច ស្តីពីការបង្កើតគណៈកម្មាការជ្រើសរើសមន្ត្រីវាយតំលៃគុណភាពអប់រំឧត្តមសិក្សារបស់**គ.ទ.ក** ។

-អគ្គលេខាធិការដ្ឋានបានជ្រើសរើសមន្ត្រីវាយតំលៃ តាមនីតិវិធីដែលបានកំណត់ បានចំនួន៣៩រូប។ មន្ត្រីវាយតំលៃទាំងនោះត្រូវបានធ្វើការបណ្តុះបណ្តាលចំនួនពីរលើក លើកទី១ នៅថ្ងៃទី ១៨ និង ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ដែលឧបត្ថម្ភថវិកាដោយអង្គការបណ្តាញធានាគុណភាពអាស៊ីប៉ាស៊ីហ្វិក (APQN) នៅសណ្ឋាគារ ភ្នំពេញ និង លើកទី២ នៅថ្ងៃទី ២៨ ខែ ធ្នូ ២០០៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី។

-អគ្គលេខាធិការដ្ឋានបានរៀបចំសេចក្តីព្រាងក្រមសីលធម៌សំរាប់មន្ត្រីវាយតំលៃគុណភាពអប់រំឧត្តមសិក្សា។

## គ- ការរៀបចំស្តង់ដារអប្បរមារ

យោងតាមស្មារតីនៃព្រះរាជក្រឹត្យ លេខ ០៣០៣/១២៩/រកត ចុះថ្ងៃទី ៣១ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា **គ.ទ.ក** ត្រូវបង្កើតស្តង់ដារអប្បរមាមួយដែលមានលក្ខណៈវិនិច្ឆ័យ៩សំរាប់ជាមូលដ្ឋានក្នុងវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា ដើម្បីផ្តល់ការទទួលស្គាល់គុណភាពអប់រំ។

ក្នុងដំណើរការរៀបចំស្តង់ដារអប្បរមារ នាយកដ្ឋានស្តង់ដារនិងការទទួលស្គាល់គុណភាពអប់រំ នៃអគ្គលេខាធិការដ្ឋាន**គ.ទ.ក** បានរៀបចំសេចក្តីព្រាងស្តង់ដារអប្បរមារួចហើយទាំងភាសាខ្មែរ និង អង់គ្លេស និងបានដាក់ជូនអ្នកជំនាញការបរទេសពិនិត្យនិងកែសំរួលបានចំនួនពីរលើករួចហើយដែរ។ លើកទីមួយបានដាក់ឱ្យអ្នកជំនាញការបរទេសមកពី Fulbritgh សហរដ្ឋអាមេរិក គឺលោកស្រីបណ្ឌិត Dr. Amy Kirle Lezberg ពិនិត្យ កែសំរួល និងផ្តល់អនុសាសន៍ និង លើកទីពីរ បានដាក់ឱ្យទីប្រឹក្សាបរទេសរបស់ **គ.ទ.ក** មកពី ប្រទេសហ្វីលីពីន គឺលោកស្រីបណ្ឌិត Dr. Concepcion V. Pijano ពិនិត្យ កែសំរួល និងផ្តល់អនុសាសន៍ ម្តងទៀត ។

សេចក្តីព្រាងស្តង់ដារអប្បរមារនេះនឹងត្រូវលើកជាកម្មវត្ថុនៃអង្គសិក្ខាសាលានាពេលខាងមុខ ដើម្បីប្រមូលយោបល់ និងសំណូមពរពីគ្រឹះស្ថានឧត្តមសិក្សានានាមុននឹង **គ.ទ.ក** អនុម័តនិងដាក់ឱ្យអនុវត្តជាផ្លូវការ។

# ២-ការងារកិច្ចសហប្រតិបត្តិការនិងព័ត៌មាន

## ក-ការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ

### ក.១- ការតែងតាំងទីប្រឹក្សាបរទេសសំរាប់ គ.ទ.ក

នៅថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៥ គណៈកម្មធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា បានតែងតាំងលោក ស្រីបណ្ឌិត Dr. Concepcion V Pijano, Executive Director Philippine Accrediting Association of Schools Colleges and Universities (PAASCU) មកពីប្រទេសហ្វីលីពីន ជាទីប្រឹក្សាបរទេសរបស់ **គ.ទ.ក** ។

### ក.២-កិច្ចសហប្រតិបត្តិការជាមួយធនាគារពិភពលោក

ធនាគារពិភពលោកបានផ្តល់ជំនួយចំនួន ១លាន ដុល្លាអាមេរិកដល់ **គ.ទ.ក** ដើម្បីពង្រឹងសមត្ថភាពទាំងខាងសំភារៈ ធនធានមនុស្ស និងធានាប្រសិទ្ធភាពនៃដំណើរការទទួលស្គាល់គុណភាពអប់រំសំរាប់រយៈពេល៣ឆ្នាំ ។ ជំនួយចំនួន១លាន ដុល្លាអាមេរិកនេះ ជាផ្នែកតូចមួយនៃគំរោង CESSP (Cambodian Education Sector Support Project) របស់ក្រសួងអប់រំ យុវជន និង កីឡា ដែលមានទឹកប្រាក់ចំនួន ៣០លានដុល្លាអាមេរិក ដែលក្នុងនោះមាន ២០លានដុល្លាជាជំនួយឥតសំណង និង ៨លានដុល្លាជាឥណទានរបស់ធនាគារពិភពលោក ហើយ ២លានដុល្លាជាថវិកាបដិភាគរបស់រាជរដ្ឋាភិបាល។

## ក. ៣-កិច្ចសហប្រតិបត្តិការជាមួយស្ថានទូតអាមេរិក

-ស្ថានទូតអាមេរិកនៅកម្ពុជា តាមរយៈកម្មវិធី Fulbright Senior Specialist បានជួយផ្តល់អ្នកជំនាញការជាន់ខ្ពស់មួយរូបគឺលោកស្រីបណ្ឌិត Amy Kirle Lezberg មកជួយអគ្គលេខាធិការដ្ឋានក្នុងការរៀបចំស្តង់ដារអប្បរមា ដែលជាការងារសំខាន់ចាំបាច់ជាងគេរបស់ **គ.ទ.ក**។ បេសកកម្មរបស់លោកស្រីបណ្ឌិត Amy Kirle Lezberg មានរយៈពេល ៤សប្តាហ៍ ចាប់ពីថ្ងៃទី ០៧ ខែ កុម្ភៈ ដល់ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៥។

- ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៥ ស្ថានទូតសហរដ្ឋអាមេរិកប្រចាំទីក្រុងភ្នំពេញបានអញ្ជើញតំណាងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ទៅចូលរួមកម្មវិធីភ្ញៀវអន្តរជាតិដើម្បីសិក្សាស្វែងយល់អំពី **រដ្ឋបាលសាកលវិទ្យាល័យ** （The international visitor program on University Administration）ពីថ្ងៃទី ៦-២៧ ខែ មេសា ឆ្នាំ ២០០៦ ។

## ក.៤-កិច្ចសហប្រតិបត្តិការជាមួយ APQN

អគ្គលេខាធិការដ្ឋានគ.ទ.ក បានធ្វើកិច្ចសហប្រតិបត្តិការយ៉ាងល្អជាមួយ អង្គការ APQN (Asia-Pacific Quality Network) ។

កិច្ចសហប្រតិបត្តិការអន្តរជាតិនេះ ជាជំហានមួយទៀតដែលធ្វើអោយប្រទេសនានា ទាំងក្នុងតំបន់និងទាំងក្នុងពិភពលោកបានទទួលស្គាល់ និងស្គាល់**គ.ទ.ក** របស់កម្ពុជាដែលទើបនឹងបង្កើតថ្មី។

លទ្ធផលនៃកិច្ចសហប្រតិបត្តិការមានដូចខាងក្រោមៈ

### ក.៤.១- ការជួយបណ្តុះបណ្តាលធនធានមនុស្ស

ក្រោមជំនួយផ្នែកហិរញ្ញវត្ថុរបស់APQN នៅក្នុងឆ្នាំ ២០០៥ **គ.ទ.ក** បានបញ្ជូនតំណាងរបស់ខ្លួនទៅចូលរួម កិច្ចប្រជុំ និង សិក្ខាសាលានានានៅក្រៅប្រទេស និង ក្នុងប្រទេស ដូចខាងក្រោមៈ

-កិច្ចប្រជុំប្រចាំឆ្នាំ (General Annual Meeting) របស់ APQN និង សិក្ខាសាលាស្តីពីវេទិកាគុណភាព (Workshop on Quality Forum) ត្រូវរៀបចំឡើងនៅក្រុងហុងកុង ប្រទេសចិន ដែលបានប្រព្រឹត្តនៅថ្ងៃទី ៣១ ខែ មករា ដល់ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០៥។

- សន្និសិទប្រចាំឆ្នាំ (Annual Conference) របស់ INQAAHE ( International Network for Quality Assurance Agency in Higher Education) ស្តីពី Quality, Assurance and Diversity ត្រូវរៀបចំឡើងនៅទីក្រុង Wellington ប្រទេស New Zealand ដែលបានប្រព្រឹត្តនៅថ្ងៃទី ២៩ ខែ មីនា ដល់ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥។

-សិក្ខាសាលា ស្តីពី **វិធីសាស្ត្រវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា** ត្រូវរៀបចំឡើងនៅក្រុងម៉ានីល ប្រទេស ហ្វីលីពីន ដែលបានប្រព្រឹត្តនៅថ្ងៃទី ២៥-២៦ ខែ កក្កដា ឆ្នាំ ២០០៥។

-សិក្ខាសាលា ស្តីពី **ការគ្រប់គ្រង និង ការធានាគុណភាពរបស់ភ្នាក់ងារធានាគុណភាព** ត្រូវបានរៀបចំឡើង នៅទីក្រុង អូឡាំបាតា ប្រទេស ម៉ុងហ្គោលី ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ២៩-៣០ ខែ សីហា ឆ្នាំ ២០០៥។

-សិក្ខាសាលា ស្តីពីវេទិកាប្រចាំឆាំរបស់ Annual Forum of Australian University Quality Agency- AUQA ត្រូវបានរៀបចំឡើង នៅទីក្រុង Sydney ប្រទេស អូស្ត្រាលី ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ០៦-០៨ ខែ កក្កដា ឆ្នាំ ២០០៥។

-សិក្ខាសាលា ស្តីពីការបណ្តុះបណ្តាលអ្នកវាយតម្លៃរបស់ភ្នាក់ងារធានាគុណភាពសាកលវិទ្យាល័យអូស្ត្រាលី (Australian University Quality Agency- AUQA Auditor Training) ត្រូវបានរៀបចំឡើងនៅទីក្រុង Melburn ប្រទេសអូស្ត្រាលី ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ២៨- ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៥។

-សិក្ខាសាលា ស្តីពី **ការបណ្តុះបណ្តាលមន្ត្រីវាយតម្លៃគុណភាព** ត្រូវបានរៀបចំឡើងនៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា នៅថ្ងៃទី ១៨-១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ។ សមាសភាពចូលរួមក្នុងអង្គសិក្ខាសាលាថ្ងៃនេះមានចំនួន ៥៥ រូប ដែលក្នុងនោះមាន សមាសភាពជាតិ ចំនួន ៤០ រូប និងបរទេសចំនួន ១៥រូប ។

**ក.៤.២- ការចូលជាសមាជិករបស់ APQN**

អង្គប្រជុំរបស់អង្គការ APQN/INQAAHE នៅទីក្រុង Wellington ប្រព្រឹត្តនៅថ្ងៃទី ២៩ ខែមីនា ដល់ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥បានសំរេចអោយតំណាងរបស់ **គ.ទ.ក** មានសិទ្ធិបោះឆ្នោតជ្រើសរើសសមាជិកក្រុម ប្រឹក្សាភិបាល APQN ។

អគ្គលេខាធិការដ្ឋានបាន រៀបចំឯកសារ និង បំពេញបែបបទដើម្បី ចូលជាសមាជិកពេញសិទ្ធិរបស់អង្គការ APQN ។

**ក.៤.៣-ការជួយឧបត្ថមដល់ទីប្រឹក្សា០២រូបរបស់គ.ទ.ក**

អគ្គលេខាធិកាដ្ឋានបានស្នើសុំ APQN ដើម្បីជួយឧបត្ថម្ភទីប្រឹក្សាទាំង ០២ រូប សំរាប់រយៈពេល៣ឆ្នាំ ។ ជាលទ្ធផល APQN បានឯកភាពឧបត្ថម្ភសំរាប់មួយឆ្នាំដំបូង ចំពោះឆ្នាំទី២ និងទី៣ យើងត្រូវស្នើសុំម្តងទៀត ហើយ APQN នឹងពិនិត្យលទ្ធភាពថវិការបស់ខ្លួននៅពេលនោះជាថ្មី ។ APQN អាចជួយឧបត្ថម្ភថវិកានេះ សំរាប់តែបេក្ខជនទីប្រឹក្សាណាដែលមកពីស្ថាប័នទទួលស្គាល់គុណភាពអប់រំ ជាសមាជិករបស់APQN ប៉ុណ្ណោះ ។

ជំនួយឧបត្ថម្ភមាន ការចំណាយទៅលើ សំបុត្រយន្តហោះទៅមក ការស្នាក់នៅ អាហារប្រចាំថ្ងៃ ការធ្វើដំណើរប្រចាំថ្ងៃ និងប្រាក់កំរៃវិជ្ជាជីវៈ ។ ការជួយឧបត្ថម្ភនេះសំរាប់រយៈពេល០៥ថ្ងៃ ហើយ APQN អាចជួយ ០២ ដង ក្នុងមួយឆ្នាំ ។

**ក.៥-កិច្ចសហប្រតិបត្តិការជាមួយអង្គការ JICA**

អគ្គលេខាធិការដ្ឋាន **គ.ទ.ក** បានសហការជាមួយអង្គការ **JICA** របស់ប្រទេសជប៉ុនរៀបចំសិក្ខាសាលាមួយតាមរយៈប្រព័ន្ធបច្ចេកវិទ្យាទំនើប （Video Conference） ស្តីពីការផ្លាស់ប្តូរបទពិសោធន៍នៃការធានាគុណភាពអប់រំឧត្តមសិក្សារវាងប្រទេស ជប៉ុន និងកម្ពុជា។ នៅពេលនោះភាគីជប៉ុនបានលើកប្រធានបទស្តីពី ការបង្កើតស្តង់ដារនៃកំរិតសញ្ញាប័ត្រនៅប្រទេសជប៉ុន（ Standard Setting of Academic Degree in Japan）ចំណែកឯភាគីកម្ពុជាបានលើកប្រធានបទ ស្តីពីការផ្តល់ការទទួលស្គាល់ គុណភាពអប់រំឧត្តមសិក្សា（HEI Accreditation in Cambodia ）។ សិក្ខាសាលានេះបានប្រព្រឹត្ត ទៅនៅ ទីក្រុងតូក្យូ ប្រទេសជប៉ុនដែលរៀបចំដោយ NIAD-UE កាលពីថ្ងៃ ទី ៨ ខែឧសភា ឆ្នាំ ២០០៥ សមាសភាពរបស់កម្ពុជា មានថ្នាក់ដឹកនាំ និងមន្ត្រីអគ្គលេខាធិការដ្ឋាន **គ.ទ.ក** និងសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងនាយកនៃគ្រឹះស្ថានឧត្តមសិក្សាទាំងអស់ បានចូលរួមពិភាក្សា ផ្លាស់ប្តូរយោបល់ តាមរយៈ Video Conference នៅទីស្នាក់ការរបស់អង្គការ **JICA** ប្រចាំទីក្រុងភ្នំពេញ។

**ក.៦-កិច្ចសហប្រតិបត្តិការជាមួយអង្គការ UNESCO**

អង្គការ UNESCO ប្រចាំនៅភ្នំពេញ បានឧបត្ថមថវិកា ដល់អគ្គលេខាធិការដ្ឋាន **គ.ទ.ក** ដើម្បីបោះពុម្ព សៀវភៅណែនាំលំអិតស្តីពីដំណើរការថ្នាក់ឆ្នាំសិក្សាមូលដ្ឋានសំរាប់គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ និង សៀវភៅណែនាំស្តីពីដំណើការវាយតំលៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋានសំរាប់មន្ត្រីវាយតំលៃ និង រៀបចំសិក្ខាសាលាស្តីពីរបៀបនៃការសរសេររបាយការណ៍ស្វ័យវាយតំលៃ (Self-assessment) ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៅតាមគ្រឹះស្ថានឧត្តមសិក្សា នៅសាលសន្និសីទព្រឹទ្ធសភា នៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៥ ។

**ក.៧-កិច្ចសហប្រតិបត្តិការជាមួយមួយអង្គការ និង ប្រទេសនានា**

- ពង្រីកកិច្ចសហប្រតិបត្តិការជាមួយ AUN (Asian University Network)។ ជាលទ្ធផលបានទទួលឯកសារមួយចំនួនសំរាប់គ.ទ.ក។ លេខាធិការដ្ឋាន AUN សន្យានិងអញ្ជើញតំណាងACC ទៅចូលរួមក្នុងកិច្ចការធានាគុណភាពអប់រំនាពេលខាងមុខ។

- បានចូលរួមនៅក្នុងសន្និបាត AMEA (Asian Medical Education Association) លើកទី៣នៅទីក្រុង សេអ៊ូល ប្រទេសកូរ៉េ ស្តីពីគុណភាពអប់រំផ្នែកវេជ្ជសាស្ត្រ នៅថ្ងៃទី ២០-២៣ ខែ តុលា ឆ្នាំ ២០០៥។

-ធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថានទូតមួយចំនួនដូចជា វៀតណាម កូរ៉េ សិង្ហបុរី អាល្លឺម៉ង់ ។ល។

**ខ-ការងារកិច្ចសហប្រតិបត្តិការជាតិ**

អគ្គលេខាធិការដ្ឋាន **គ.ទ.ក** បានធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធមួយចំនួនដូចខាងក្រោម:

-បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីរៀបចំសេចក្តីព្រាងសារាចរណែនាំរបស់រាជរដ្ឋាភិបាល ស្តីពីការផ្សាយពាណិជ្ជកម្មរបស់គ្រឹះស្ថានឧត្តមសិក្សា។

-បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងការពារជាតិ និងសាកលវិទ្យាល័យអន្តរជាតិ ដើម្បីរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីលក្ខណៈវិនិច្ឆ័យបង្កើតគ្រឹះស្ថានឧត្តមសិក្សាដែលបណ្តុះបណ្តាលផ្នែកសុខាភិបាល។

-បានសហការជាមួយ ក្រសួងអប់រំ យុវជន និងកីឡា និងសាកវិទ្យាល័យចំរើនពហុបច្ចេកវិទ្យាក្នុងការរៀបចំវគ្គពិសេសបណ្តុះបណ្តាលថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ សម្រាប់មន្ត្រីរាជការវ័យចំណាស់ និងឥស្សរជន ។

-បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីរៀបចំបង្កើតគណៈកម្មាធិការពិនិត្យវាយតំលៃកំរិតសញ្ញាប័ត្រ និងលិខិតបញ្ជាក់ការសិក្សា។

**គ-ការងារពត៌មាន**

-បានចងក្រងឯកសារសាកលវិទ្យាល័យបរទេសទៅតាមតំបន់នីមួយៗចំនួន ១ច្បាប់។

-បានបង្កើតគណៈកម្មការនិពន្ធទស្សនាវដ្តី របស់ **គ.ទ.ក**។

-បានរៀបចំបង្កើតគេហទំព័រ របស់ **គ.ទ.ក** www.acc.gov.kh ដែលនឹងបង្ហោះនៅឆ្នាំ ២០០៦។

-បានតាមដានរាល់ការផ្សាយពត៌មានទាក់ទងនឹង **គ.ទ.ក** នៅតាមប្រព័ន្ធផ្សព្វផ្សាយពត៌មាន។

-បានចងក្រងទិន្នន័យកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់គ្រឹះស្ថានឧត្តមសិក្សាក្នុងប្រទេស។

## ៣-ការងារកិច្ចការទូទៅ

**ក-អំពីកិច្ចប្រជុំ គ.ទ.ក និង កិច្ចប្រជុំអគ្គលេខាធិការដ្ឋាន**

**ក.១- អំពីកិច្ចប្រជុំ គ.ទ.ក**

គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ចំនួន មួយលើកកាលពីថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៥ ក្រោមអធិបតីភាពឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាន**គ.ទ.ក** ដើម្បីពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦ នៃព្រះរាជក្រឹត្យ ស្តីពី ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា។

**ក.២- អំពី កិច្ចប្រជុំអគ្គលេខាធិការដ្ឋាន**

ដើម្បីជំរុញការអនុវត្តការងារអោយមានប្រសិទ្ធភាព និងទទួលបានជោគជ័យទៅតាមផែនការការងាររបស់ខ្លួន អគ្គលេខាធិការដ្ឋានបានប្រជុំផ្ទៃក្នុងរបស់ខ្លួន រួមមាន ប្រជុំសាមញ្ញ និង វិសាមញ្ញ ចំនួន ២៥ លើក នៅក្នុងឆ្នាំ ២០០៥ ។

**ខ-អំពីបុគ្គលិក**

នៅឆ្នាំ ២០០៥ អគ្គលេខាធិការដ្ឋានមានមន្ត្រី ចំនួន ២៤ រូប ក្នុងនោះ មន្ត្រីមានក្របខ័ណ្ឌរដ្ឋចំនួន១៧ រូប និង បុគ្គលិកជាប់កិច្ចសន្យាចំនួន ០៧ រូប។

**ង-អំពីបទដ្ឋានគតិយុត្តិ**

***លិខិតបទដ្ឋានគតិយុត្តិជាធរមានដែលពាក់ព័ន្ធនឹង គ.ទ.ក រហូតដល់ឆ្នាំ ២០០៥ រួមមាន:***

១- ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា ។

២- ព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីកែសម្រួល មាត្រា ១០ មាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៥ មាត្រា ១៦ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា។

៣- អនុក្រឹត្យលេខ ៤៦/អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។

៤- សេចក្តីសំរេចលេខ ០១/០៣ **គ.ទ.ក** ស.ស.រ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋាននៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។

៥- សេចក្តីសំរេចលេខ ០២/០៤ **គ.ទ.ក** ស.ស.រ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីលក្ខខណ្ឌសំរាប់ការចេញវិញ្ញាបនប័ត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៅតាមគ្រឹះស្ថានឧត្តមសិក្សា

៦- សេចក្តីសំរេច លេខ០៤/០៤ **គ.ទ.ក** ស.ស.រ ចុះថ្ងៃទី ១៩ ខែ វិច្ឆកា ឆ្នាំ ២០០៤ ស្តីពីកម្មវិធីសិក្សាជាប្រព័ន្ធក្រេឌីត និងការផ្ទេរក្រេឌីត នៅឧត្តមសិក្សា។

៧- បទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋាន ។

៨- សេចក្តីសំរេចលេខ០១/០៥ **គ.ទ.ក** ស.ស.រ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការជ្រើសរើសមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា។

៩- សេចក្តីណែនាំ លេខ ៤៨/០៥ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៥ លំអិតស្តីពី ដំណើរការថ្នាក់ឆ្នាំសិក្សាមូលដ្ឋានសំរាប់គ្រឹះស្ថានឧត្តមសិក្សា។

១០- សេចក្តីណែនាំ លេខ ៤៩/០៥ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្តីពី ដំណើរការវាយតំលៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋានសំរាប់អ្នកវាយតំលៃ ។

## II- **ទិសដៅការងារនាពេលខាងមុខ**

កិច្ចការបន្តដែលត្រូវធ្វើក្នុងឆ្នាំ២០០៦ ខាងមុខ មានដូចខាងក្រោម ÷

-សិក្សាបញ្ចប់ស្តង់ដារអប្បរមារសំរាប់ផ្តល់ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

-បង្កើតឧបករណ៍ស្វ័យវាយតំលៃសំរាប់ការទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សា

-រៀបចំសេចក្តីណែនាំសំរាប់គ្រឹះស្ថានឧត្តមសិក្សាពីរបៀបប្រើប្រាស់ឧបករណ៍ស្វ័យវាយតំលៃ

-រៀបចំសៀវភៅណែនាំមន្ត្រីវាយតំលៃសំរាប់ការចុះវាយតំលៃគ្រឹះស្ថានឧត្តមសិក្សា

-រៀបចំសៀវភៅស្តីពីគោលនយោបាយ និងនីតិវិធី របស់អគ្គលេខាធិការដ្ឋាន**គ.ទ.ក**

-បង្កើតគ្រោងការគុណវុឌ្ឍន៍សិក្សាសំរាប់ការអប់រំឧត្តមសិក្សា

-បន្តកិច្ចសហប្រតិបត្តិការនេះបន្តទៀត ដើម្បីសុំចូលជាសមាជិក របស់ INQAAHE និងស្វែងរកជំនួយហិរញ្ញវត្ថុផ្សេងទៀត

-ត្រូវការអ្នកជំនាញការបរទេសដើម្បីរៀបចំបទដ្ឋានខាងលើ

-រៀបចំសិក្ខាសាលា និងកម្មសិក្សាមួយចំនួនទាំងក្នុងប្រទេស និងក្រៅប្រទេស

- កំណត់នីតិវិធីក្នុងការផ្តល់ការទទួលស្គាល់គុណភាពអប់រំ ដល់គ្រឹះស្ថានឧត្តមសិក្សា

- កំណត់គោលការណ៍សំរាប់ផ្តល់ការយល់ព្រមដល់គ្រឹះស្ថានឧត្តមសិក្សា ក្នុងការកំណត់លក្ខខណ្ឌសំរាប់និស្សិតវ័យចំណាស់ និងនិស្សិតមកពីគ្រឹះស្ថានមធ្យមសិក្សាបច្ចេកទេស ឬ គ្រឹះស្ថានសិក្សាក្រោយមធ្យមសិក្សាទុតិយភូមិ

- បន្តកិច្ចសហប្រតិបត្តិការជាតិ និង អន្តរជាតិដើម្បីស្វែងរកជំនួយបច្ចេកទេស និង ហិរញ្ញវត្ថុ

- បន្តកិច្ចសហប្រតិបត្តិការ ជាមួយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត

- បង្ហោះ គេហទំព័រ **www.acc.gov.kh** របស់គ.ទ.ក តាមប្រព័ន្ធ Internet

- ជ្រើសរើសបុគ្គលិកដែលមានសញ្ញាប័ត្រខ្ពស់មួយចំនួនបន្ថែមទៀត

- បន្តអនុវត្តភារកិច្ចចាំបាច់មួយចំនួនទៀតរបស់អគ្គលេខាធិការដ្ឋាន **គ.ទ.ក** ។

## III-**សេចក្តីសន្និដ្ឋាន**

- ដោយសារតែមានការគាំទ្រយ៉ាងខ្លាំងពីរាជរដ្ឋាភិបាល និងពីសំណាក់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ព្រមទាំងការខិតខំប្រែងរបស់ថ្នាក់ដឹកនាំនិងមន្ត្រីទាំងអស់របស់អគ្គលេខាធិការដ្ឋាន ក្នុងឆ្នាំ២០០៥កន្លងមក អគ្គលេខាធិការដ្ឋានបានបំពេញភារកិច្ចទៅតាមផែនការការងាររបស់ខ្លួនប្រកបដោយជោគជ័យ និងទទួលលទ្ធផលល្អ ទាំងការងារផ្ទៃក្នុង និង ការងារកិច្ចសហប្រតិបត្តិការជាតិ និង អន្តរជាតិក្នុងស្វែងរកជំនួយហិរញ្ញវត្ថុ និង បច្ចេកទេស ។

- ក្នុងឆ្នាំ២០០៥នេះ អគ្គលេខាធិការដ្ឋានបានបំពេញភារកិច្ចរបស់ខ្លួននៅក្នុងដំណាក់កាលនៃកសាងបទដ្ឋានគតិយុត្តិនានាដែលជាឧបករណ៍ ឬ ជាខ្នាតសំរាប់ការវាយតំលៃ និងផ្តល់ការទទួលស្គាល់គុណភាពអប់រំដល់គ្រប់គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ។

- ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់របស់អគ្គលេខាធិការដ្ឋាន បានខិតខំយកចិត្តទុកបំពេញការងារ

ប្រកបដោយស្មារតីទទួលខុសត្រូវលើភារកិច្ចរបស់ខ្លួន ដើម្បីជំរុញល្បឿនការងារអោយបានឆាប់រហ័ស និង ប្រកបដោយប្រសិទ្ធភាព។ ប៉ុន្តែការខ្វះខាតសំភារៈមួយចំនួន ដូចជា : Computer Printer ម៉ាស៊ីនថតចំលង និងសំភារៈការិយាល័យមួយចំនួនទៀត ក៏ជាមូលហេតុធ្វើអោយការងារយឺតយ៉ាវផងដែរ។ ទន្ទឹមនឹងនោះដែរ យើងក៏ត្រូវការចាំបាច់អ្នកជំនាញការបរទេសផងដែរ ដើម្បីជួយការងារបច្ចេកទេស ព្រោះនេះជាការងារមួយថ្មីណាស់សំរាប់យើងទាំងអស់គ្នា។